# កម្រងសិទ្ធិឯកកត្តជនអ្នកបោះឆ្នោត

1. អ្នកមានសិទ្ធិបោះឆ្នោត ប្រសិនបើអ្នកជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះត្រឹមត្រូវ។
   អ្នកបោះឆ្នោតដែលបានចុះឈ្មោះបានត្រឹមត្រូវមានន័យថាជាសញ្ជាតិអាមេរិកដែលជាពលរដ្ឋនៅក្នុងរដ្ឋនេះដែលមានអាយុយ៉ាងតិច 18 ឆ្នាំ និងមិនជាប់ពន្ធនាគារឬត្រូវដោះលែងមានល័ក្ខខ័ណ្ឌសំរាប់ការប្រព្រឹត្តបទឧក្រិដ្ឋ ធ្ងន់ធ្ងរហើយបានចុះឈ្មោះបោះឆ្នោតនៅអាស័យដ្ឋានរស់នៅបច្ចុប្បន្នរបស់គេ។
2. អ្នកមានសិទ្ធិបោះឆ្នោតបណ្តោះអាសន្ន ប្រសិនបើឈ្មោះរបស់អ្នកមិនត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត។
3. អ្នកមានសិទ្ធិបោះឆ្នោតប្រសិនបើអ្នកមានវត្តមាននៅក្នុងជួររង់ចាំនៅកន្លែងបោះឆ្នោតមុនពេលបិទការបោះឆ្នោត។
4. អ្នកមានសិទ្ធិបោះឆ្នោតជាសំងាត់ដោយគ្មានការគំរាមកំហែង។
5. អ្នកមានសិទ្ធិទទួលបាននូវសន្លឹកឆ្នោតថ្មីប្រសិនបើមុនពេលការបោះឆ្នោតរបស់អ្នក អ្នកជឿថាអ្នកបានធ្វើខុស។ ប្រសិនបើនៅពេលណាក៏ដោយ មុនពេលអ្នកសំរេចចិត្តចុងក្រោយថាបោះសន្លឹកឆ្នោតរបស់អ្នក ហើយអ្នកមានអារម្មណ៍ថា អ្នកបានធ្វើខុស អ្នកមានសិទ្ធិសុំដូរសន្លឹកឆ្នោតដែលខូចសំរាប់សន្លឹកឆ្នោតថ្មី។ អ្នកបោះឆ្នោតតាមសំបុត្រ អាចស្នើសុំ និងទទួលសន្លឹកឆ្នោតថ្មីប្រសិនបើពួកគេបញ្ជូនសន្លឹកឆ្នោតដែលខូចរបស់ពួកគេទៅឱ្យមន្ត្រីបោះឆ្នោតមុនពេលបិទការបោះឆ្នោតនៅថ្ងៃបោះឆ្នោត។
6. អ្នកមានសិទ្ធិទទួលបាននូវការជួយសំរួលក្នុងការបោះឆ្នោតរបស់អ្នក ប្រសិនបើអ្នកមិនអាចបោះឆ្នោតបានដោយគ្មានការជួយជ្រោមជ្រែង។
7. អ្នកមានសិទ្ធិបញ្ជូនត្រឡប់មកវិញនូវសន្លឹកឆ្នោតតាមសំបុត្រដែលបំពេញរួច ទៅកាន់ការិយាល័យបោះឆ្នោតណាមួយនៅក្នុងតំបន់។
8. អ្នកមានសិទ្ធិជ្រើសរើសឯកសារបោះឆ្នោតជាភាសាមួយផ្សេងទៀត ប្រសិនបើ មានពលរដ្ឋគ្រប់គ្រាន់នៅមណ្ឌលបោះឆ្នោតរបស់អ្នកដើម្បធានានូវផលិតផល។
9. អ្នកមានសិទ្ធិសួរសំណួរអំពីនីតិវិធីបោះឆ្នោតនិងសង្កេតដំណើរការបោះឆ្នោត។
   អ្នកមានសិទ្ធិសួរសំណួរអំពីគណៈកម្មការមណ្ឌលបោះឆ្នោតនិងមន្ត្រីបោះឆ្នោតពាក់ព័ន្ធនឹងនីតិវិធីបោះឆ្នោត និងដើម្បីទទួលបាននូវចំឡើយ ឬការណែនាំបន្តទៅកាន់មន្ត្រីសមស្របដែលអាចផ្តល់ចំឡើយបាន។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើការសួរសំណួរមិនអស់មិនហើយមានការរំខានដល់ការអនុវត្តតួនាទីរបស់ពួកគេគណៈកម្មការ ឬមន្ត្រីបោះឆ្នោតអាចបញ្ឈប់ការឆ្លើយតបនឹងសំណួរបាន។
10. អ្នកមានសិទ្ធិរាយការណ៍នូវសកម្មភាពខុសច្បាប់ ឬការក្លែងបន្លំទៅកាន់មន្ត្រីបោះឆ្នោតក្នុងតំបន់ ឬទៅកាន់ការិយាល័យរដ្ឋលេខាធិការ។

**ប្រសិនបើអ្នកជឿជាក់ថាអ្នកត្រូវបានគេបដិសេធនូវសិទ្ធិទាំងនេះ**
**ឬអ្នកដឹងថាមានការបន្លំការបោះឆ្នោតឬការប្រព្រឹត្តមិនគប្បី**
**សូមទូរស័ព្ទមកលេខសំងាត់ទាន់ហេតុការណ៍សំរាប់អ្នកបោះឆ្នោតដោយឥតគិតថ្លៃគឺ (888) 345-4917។**

ព័ត៌មាននៅលើលិខិតថ្លែងសច្ចាចុះឈ្មោះបោះឆ្នោតរបស់អ្នកនឹងត្រូវប្រើដោយមន្ត្រីបោះឆ្នោតដើម្បីផ្ញើឱ្យអ្នកនូវព័ត៌មានផ្លូវការចំពោះដំណើរការបោះឆ្នោត ដូចជាទីកន្លែងបោះឆ្នោតរបស់អ្នកនិងបញ្ហានានា ព្រមទាំងបេក្ខជនដែលនឹងមាននៅលើសន្លឹកឆ្នោត។ ការប្រើជាលក្ខណៈ ពាណិជ្ជកម្មនៃព័ត៌មានចុះឈ្មោះអ្នកបោះឆ្នោតគឺត្រូវបានហាមប្រាមដោយច្បាប់និងចាត់ទុកជាបទល្មើសមជ្ឈឹម។ ព័ត៌មានអ្នកបោះឆ្នោតអាចត្រូវផ្តល់ជូនដល់បេក្ខជនឈរឈ្មោះគណៈកម្មការវិធានការបោះឆ្នោត ឬបុគ្គលសំរាប់គោលបំណងការបោះឆ្នោត ការសិក្សា សារព័ត៌មាន នយោបាយ ឬរដ្ឋាភិបាល ដូចដែលបានកំណត់ដោយរដ្ឋលេខាធិការ។ ប័ណ្ណបើកបរនិងលេខសុវត្ថិភាពសង្គម (social security numbers) ឬហត្ថលេខារបស់អ្នកដូចដែលមានបង្ហាញនៅលើកាតចុះឈ្មោះបោះឆ្នោត មិនអាចត្រូវបានបញ្ចេញសំរាប់គោលបំណង ទាំងនោះទេ។ ប្រសិនបើអ្នកមានសំណួរអ្វីអំពីការប្រើព័ត៌មានអ្នកបោះឆ្នោតឬមានបំណងរាយការណ៍នូវការប្រើខុសដែលសង្ស័យនូវព័ត៌មានដូចនេះសូមទូរស័ព្ទមកលេខទាន់ហេតុការណ៍សំរាប់អ្នកបោះឆ្នោតរបស់រដ្ឋលេខាធិការគឺ (888) 345-4917។

អ្នកបោះឆ្នោតមួយចំនួនដែលប្រឈមមុខនឹងស្ថានភាពគំរាមកំហែងដល់ជីវិតអាចមានសិទ្ធិសំរាប់ស្ថានភាពអ្នកបោះឆ្នោតជាសំងាត់។ សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងមកលេខឥតគិតថ្លៃរបស់កម្មវិធីសុវត្ថិភាពនៅផ្ទះរបស់រដ្ឋលេខាធិការគឺ (877) 322-5227 ឬ ទៅកាន់គេហទំព័ររបស់រដ្ឋលេខាធិការគឺ *www.sos.ca.gov*។